# សង្ខេបប្រវត្តិសាស្ត្រប្រទេសកម្ពុជា

***ដោយ ដេវីដ ឆែនល័រ***

*ប្រែសម្រួលដោយ គ្រី ស៊ុយហៀង កែសម្រួលដោយ ញាណ សុជាតិ*

*(អត្ថបទខាងក្រោមនេះ ត្រូវបានរៀបចំឡើងសម្រាប់គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងវគ្គហ្វឹកហ្វឺនគ្រូបង្គោលថ្នាក់ជាតិសម្រាប់បង្រៀន នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យទូទាំងប្រទេសកម្ពុជា ដែលប្រារព្ធធ្វើឡើងនៅបណ្ណាល័យព្រឹទ្ធសភា ទីក្រុងភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃ ទី៧ ខែកក្កដា ឆ្នាំ២០០៩ ។ គម្រោងនេះ គឺរួមសហការជាមួយក្រសួងអប់រំយុវជននិងកីឡា ហើយត្រូវបានគាំទ្រ និងផ្តល់ថវិកាដោយប្រទេសបែលហ្ស៊ិក កម្ពុជា កាណាដា ដេនម៉ាក អាល្លឺម៉ង់ ញ៉ូវហ្ស៊ីឡែន ន័រវេស ស៊ុយអ៊ែត សហរដ្ឋអាមេរិក ទាយជ្ជទានជាតិសម្រាប់ប្រជាធិបតេយ្យ វិទ្យាស្ថានស៊ីករីត និងវិទ្យាស្ថានសង្គម បើកចំហ) ។*

*នេះជាកិត្តិយសខ្លាំងណាស់ដែលខ្ញុំមានវត្តមាននៅទីនេះ ហើយនេះក៏ជាការខិតខំដ៏លំបាកមួយក្នុងការផ្តល់នូវប្រវត្តិសាស្ត្រកម្ពុជាដ៏យូរលង់មួយរហូតមកទល់នឹងពេលដែលកម្ពុជាទទួលបានឯករាជ្យ ដែលមានរយៈពេលពីរពាន់ឆ្នាំ ឬក៏ច្រើនជាងនេះឲ្យបានច្បាស់លាស់តែក្នុងរយៈពេលកន្លះម៉ោងនោះ ។*

*មនុស្សភាគច្រើន ជាពិសេសជនបរទេសតែងតែគិតទៅលើប្រវត្តិសាស្ត្រកម្ពុជាតែក្នុងអំឡុងសម័យកាលអង្គរ និងសម័យទំនើប ឬក៏ថាឲ្យច្បាស់ជាងនេះ គឺសម័យអង្គរ និងសម័យខ្មែរក្រហមប៉ុណ្ណោះ ។ ដូចដែលខ្ញុំចង់បង្ហាញនៅក្នុងការនិយាយដោយសង្ខេបរបស់ខ្ញុំ គឺកម្ពុជាមានប្រវត្តិច្រើនលើសពីអ្វីដែលខ្ញុំបានលើកឡើងទៅទៀត ។*

*ខ្ញុំចង់ឲ្យអ្នកទាំងអស់គ្នាយល់ថា រាល់ប្រវត្តិសាស្ត្ររបស់កម្ពុជារាប់តាំងពីសម័យកាលដ៏យូរលង់មកហើយរហូតមកទល់នឹងឆ្នាំ២០០៩នេះ គឺមានភាពសម្បូរសប្បាយគួរឲ្យចាប់អារម្មណ៍ និងមានលក្ខណៈ បន្តបន្ទាប់គ្នាឥតដាច់ ។ អ្នកទាំងអស់គ្នាគួរតែមានមោទនភាពក្នុងនាមជាទាយាទនៃប្រវត្តិសាស្ត្រ ដ៏អស្ចារ្យ និងយូរអង្វែងមួយនេះ ។*

និយាយរួម ខ្ញុំសូមបែងចែកប្រវត្តិសាស្ត្រដ៏យូរលង់នេះ ជាបួនសម័យកាលដោយរាប់ចាប់ពីការកកើតដំបូងនៃប្រវត្តិសាស្ត្រកម្ពុជារហូតដល់ឆ្នាំ១៩៥៣ ជាពេលដែលកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ។ សម័យកាលនីមួយៗអាចនឹងត្រូវមើលឃើញថាមានសាច់រឿងគោលមួយឬក៏ពីរ ។

## បុរេប្រវត្តិសាស្ត្រ ៖ សម័យហ្វូណននិងសម័យចេនឡា - ការទទួលឥទ្ធិពលពីឥណ្ឌា ៥០០០ឆ្នាំមុនគ.ស ដល់ឆ្នាំ៨០០នៃគ.ស

យើងមានភស្តុតាងបញ្ជាក់ថា មានមនុស្សរស់នៅក្នុងរូងថ្មនៅភាគពាយ័ព្យប្រទេសកម្ពុជា ជាយូរលង់ណាស់មកហើយ គឺចាប់ពី៥០០០ឆ្នាំមុនគ្រិស្តសករាជមកម្ល៉េះ ។ មនុស្សទាំងនោះ ស្ថិតនៅក្នុងយុគសម័យមួយដែលបានរស់នៅជាច្រើនកន្លែង ហើយរហូតមកដល់សព្វថ្ងៃនេះ កន្លែងជាច្រើននៃសម័យកាលនោះ ទើបនឹងត្រូវជីកកកាយដើម្បីសិក្សា ។ មកដល់១០០០ឆ្នាំមុនគ.ស មនុស្សរស់នៅតំបន់ដែលបច្ចុប្បន្នស្ថិតនៅជិតខេត្តកំពង់ឆ្នាំង បានប្រើប្រាស់ស្ពាន់ធ្វើជារបស់របរប្រើប្រាស់ (របស់របរល្អៗជាច្រើនរបស់ក្រុមមនុស្សទាំងនេះមានតាំងនៅសារមន្ទីរជាតិ) ។ របស់របរប្រើប្រាស់ឧបករណ៍លម្អផ្សេងៗ និងអាវុធមានលក្ខណៈប្រហាក់ប្រហែលនឹងវត្ថុដែលគេរកឃើញនៅទីតាំងដែលស្គាល់ថាជា "យុគសម័យស្ពាន់" ស្ថិតនៅភាគឦសានប្រទេសថៃ ។ ប៉ុន្តែវាមិនមែនមានន័យថា ជនជាតិដើមរបស់កម្ពុជាជាថៃនោះទេ ។ ត្រូវចងចាំថា ពុំមានព្រំដែនរវាងប្រទេសនីមួយៗនៅអាស៊ីអាគ្នេយ៍ទេរហូតមកដល់សម័យកាលអាណានិគម ។ ដូច្នេះ ក្រុមមនុស្សដើមដែលបច្ចុប្បន្នស្ថិតនៅភាគឦសានប្រទេសថៃប្រហែលនៅប្រើប្រាស់ភាសាខ្មែរនៅឡើយ ឬក៏ជាភាសាដែលស្រដៀងនឹងភាសាខ្មែរដែរ ។ មនុស្សទាំងនោះធ្វើស្រែ និងបរិភោគត្រីជាអាហារ ដូច្នេះរបបអាហារសំខាន់ ដែលប្រជាជនកម្ពុជារស់នៅតាមជនបទក្នុងឆ្នាំ២០០៩នេះ គឺដូចគ្នានឹងរបបអាហារដែលមនុស្សបរិភោគកាលពី១០០០ឆ្នាំមុនគ.សដែរ ។ នេះអាចបង្ហាញអំពីទំនាក់ទំនងគ្នាឥតដាច់នៃប្រវត្តិសាស្ត្រកម្ពុជា ។

ព្រឹត្តិការណ៍នេះ ខ្ញុំឲ្យឈ្មោះថា "ការទទួលឥទ្ធិពលពីឥណ្ឌា" ដែលខ្ញុំបានជ្រើសជាសាច់រឿងគោលនៃសម័យកាលនេះ ។ សម័យកាលនេះទើបតែកត់ត្រាឡើងនៅប៉ុន្មានឆ្នាំដំបូងនៃសម័យកាលគ្រិស្តសាសនាប៉ុណ្ណោះ ដែលគ្រឿងអលង្ការនិងរបស់របរប្រើប្រាស់របស់ប្រជាជនឥណ្ឌាត្រូវបានរកឃើញនៅតាមតំបន់ឆ្នេរដែលសម្បូរទៅដោយអ្នកប្រាជ្ញជាច្រើន ។ សម័យកាលនោះហើយ ដែលជនជាតិចិន ហៅថាសម័យហ្វូណន ។

ហ្វូណន ជារដ្ឋពាណិជ្ជកម្មដ៏សំខាន់មួយ ដោយសារជាទីតាំងសម្បូរទៅដោយទំនាក់ទំនងផ្លូវទឹកជាច្រើន ដែលអាចផ្ដល់កម្លាំងពលកម្មដ៏មហិមានៅពេលដែលមានតម្រូវការ ។ ប៉ុន្តែជាអកុសល ពុំមានឯកសារសំណេរណាមួយនៅសេសសល់ទេបន្ទាប់ពីសម័យកាលនោះ ។ ព័ត៌មានទាំងឡាយអំពីសម័យកាលនោះ បានមកពីកំណាយជាច្រើននៃក្រុមបុរាណវិទូ និងឯកសារជាច្រើនទៀតបានមកពីប្រទេសចិន ដែលត្រូវបានចងក្រងឡើងរាប់រយឆ្នាំមកហើយ ។ ឯកសារដែលបានមកពីប្រទេសចិនគឺមានប្រយោជន៍ណាស់ ពីព្រោះឯកសារទាំងនោះបានធ្វើការពិនិត្យមើលទៅលើភាពប្រែប្រួលនៃសម័យហ្វូណន ដោយសារអ្នកគ្រប់គ្រងនៃសម័យកាលនេះបានជ្រើសយកភាសា វប្បធម៌ និងលក្ខណៈធ្វើកិច្ចការរដ្ឋបាលពីប្រទេសឥណ្ឌាប្រកបដោយដំណើរការដ៏ប្រសើរ និងស្មុគស្មាញមួយ ដែលយើងឲ្យឈ្មោះថា «ការទទួលឥទ្ធិពលពីឥណ្ឌា» ។

ការទទួលឥទ្ធិពលពីឥណ្ឌានេះមិនមែនមានន័យថា ប្រទេសកម្ពុជាបានធ្លាក់ក្នុងអាណានិគមឥណ្ឌានោះទេ ប៉ុន្តែជាជម្រើសមួយដែលក្រុមវរជននៅសម័យនោះបានយកមកប្រើប្រាស់ នៅពេលដែលពួកគេបានប្រទះនឹងវប្បធម៌របស់ឥណ្ឌានៅប្រទេសឥណ្ឌា ដូចជាអ្នកកាន់សាសនាឬតាមរយៈការធ្វើពាណិជ្ជកម្ម ឬនៅប្រទេសកម្ពុជា (ហ្វូណន) តាមរយៈអ្នកធ្វើជំនួញឥណ្ឌា អ្នកធ្វើការ និងអ្នកដឹកនាំសាសនាជាដើម ។ ដំណើរការនៃការទទួលឥទ្ធិពលនេះកើតឡើងនៅចន្លោះ ៥០០ឆ្នាំមុនគ.ស និង៥០០ឆ្នាំក្រោយគ.ស ឬមុននិងក្រោយនេះបន្តិច ដែលដំណើរការនេះពុំត្រូវបានកត់ត្រាឡើងឡើយ ។ ដំណើរការនេះកើតឡើងដោយសារទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជាដែលបានលក់ផលិតផលដ៏កម្រពីព្រៃឈើ ហើយឥណ្ឌាទិញយកផលិតផលទាំងនេះ ដើម្បីផលិតរបស់របរជាច្រើន ជាពិសេសផលិតក្រណាត់ផ្សេងៗ ។ ឥទ្ធិពលវប្បធម៌ឥណ្ឌាដែលកម្ពុជាទទួលខ្លាំងបំផុតនោះ គឺអាទិទេព (ដែលមានប្រជាប្រិយភាពខុសៗគ្នា) និងទស្សនៈនៃការរៀបចំការគ្រប់គ្រង ។ ប៉ុន្តែ ខ្មែរពុំដែលយករបៀបបែងចែកវណ្ណៈដែលមានមកពីឥណ្ឌាមកអនុវត្តទេ ។ នៅពេលដែលភាសា«ខ្មែរ» បានក្លាយទៅជាភាសាសរសេរនៅប្រហែល៣០០ឆ្នាំក្រោយគ.សនោះ តួអក្សរឥណ្ឌាត្រូវបានកែសម្រួលសម្រាប់ជាព្យញ្ជនៈនៃភាសាថ្មីនេះ ។ ការទទួលឥទ្ធិពលពីឥណ្ឌាមិនមែនជាលើកដំបូង ហើយក៏មិនមែនជាលើកចុងក្រោយដែរចំពោះលក្ខណៈលាយឡំនិងការយកលំនាំតាមវប្បធម៌ផ្សេងៗបង្កើតជាប្រវត្តិសាស្ត្រវប្បធម៌មួយសម្រាប់ប្រទេសនេះ ។ ចំណុចសំខាន់នោះគឺថា ការទទួលឥទ្ធិពលពីឥណ្ឌានេះមិនមែនជាការដាក់ ការគ្រប់គ្រង ឬអាណានិគមដូចករណីចិនធ្វើមកលើវៀតណាមខាងជើងនោះទេ ។

នៅសតវត្សរ៍ទី៨និងទី៩ ក្រោយគ.ស ទីតាំងរដ្ឋបាលសំខាន់បានប្តូរពីតំបន់ឆ្នេរនៅលើដែនដីនៃអាណាចក្រហ្វូណនទៅភាគខាងត្បូងនៃកម្ពុជា ដោយមានទីក្រុងមួយដែលបច្ចុប្បន្នជាភូមិមួយនៅស្រុកអង្គរបុរី ។ "ត្បសានបុរៈ"ជាឈ្មោះដែលចិនបានដាក់ឲ្យអាណាចក្រនេះ ។ រាជធានីនៃចេនឡាប្រហែលជា"ឥសានាភុរា" ឬស្គាល់ថាសម្បូរព្រៃគុហ៍នៅខេត្តកំពង់ធំ ។ នៅអំឡុងរយៈពេលប៉ុន្មានឆ្នាំនោះហើយ ដែលមានការចារឹកជាភាសាខ្មែរនិងសំស្ក្រឹតនៅលើផ្ទាំងថ្មជាលើកដំបូង និងចាប់ផ្តើមមានការរៀបចំចងក្រងឯកសារស្តីអំពីសង្គមនិងប្រវត្តិរបស់កម្ពុជា ។ កិច្ចការដ៏មានសារប្រយោជន៍របស់លោក ម៉ៃខល វីឃើរី ដែលសិក្សាលើសិលាចារឹកទាំងនេះត្រូវបានបង្ហាញឡើងនៅក្នុងឆ្នាំ២០០៥ ហើយបានផ្លាស់ប្តូរការយល់ដឹងរបស់យើងចំពោះប្រវត្តិសាស្ត្រនៅប៉ុន្មានឆ្នាំចុងក្រោយនៃសម័យកាលនេះ ។

## សម័យអង្គរ-អំណាចរាជាធិរាជ នគរូបនីយកម្មនិងប្រជាជនសាមញ្ញ ឆ្នាំ៨០០ ដល់ឆ្នាំ១៤៥០នៃគ.ស ។

អ្នករាល់គ្នាតែងតែនឹកឃើញដល់អង្គរជារៀងរាល់ថ្ងៃ ដូចជានៅពេលដែលអ្នកឃើញទង់ជាតិកម្ពុជា ឬភ្លេងជាតិឬឈ្មោះហាងទំនិញនានាជាដើម ។ អ្នកក៏អាចឃើញកំពូលប្រាសាទដែលមានលក្ខណៈស្រដៀងនឹងអង្គរចេញពីវិមានឯករាជ្យដែរ ។ ភាគច្រើននៃអ្នកទាំងអស់គ្នាសុទ្ធសឹងតែបានទៅទស្សនាអង្គរហើយ អ្នកខ្លះថែមទាំងបានទស្សនាជាច្រើនលើកទៀតផង ។ អង្គរ គឺជាមណ្ឌលទេសចរណ៍ដ៏គួរឲ្យស្ញប់ស្ញែងសម្រាប់អ្នកទេសចរណ៍ដែលមកទស្សនាប្រមាណជាង១លាននាក់ក្នុងមួយឆ្នាំ ប៉ុន្តែសម្រាប់អ្នកដែលជាជនជាតិខ្មែរវិញនោះ អង្គរគឺជាអ្វីដែលខុសពីអ្នកទេសចរណ៍បរទេសទាំងនេះ ៖ អង្គរជាទីរំឭកដ៏ស្អាតអស្ចារ្យនៃភាពជោគជ័យរបស់បុព្វបុរសខ្មែរផ្នែកសិល្បៈ និងស្ថាបត្យកម្ម ការរៀបចំទីក្រុង ការធ្វើផ្លូវថ្នល់ និងវិស្វកម្មដោយប្រើប្រាស់កម្លាំងទឹក ដែលនេះគ្រាន់តែការរៀបរាប់ត្រួសៗប៉ុណ្ណោះ ។

ជាច្រើនឆ្នាំមកហើយ បុរាណវិទ្យានៅកម្ពុជាដែលគ្រប់គ្រងដោយបារាំងនោះបានសិក្សាតែអំពីព្រះរាជាប្រាសាទ និងសិលាចារឹកដែលគេរកឃើញនៅអង្គរ ដើម្បីបង្កើតជារូបភាពមួយ និងកាលបរិច្ឆេទនៃរាជាណាចក្រប៉ុណ្ណោះ ។ ការសិក្សានោះបានឲ្យឈ្មោះស្តេចចំនួន២៦អង្គដែលធាតុរបស់ស្តេចទាំងនោះមានតម្កល់នៅប្រាសាទជាងមួយពាន់ និងបកប្រែសិលាចារឹកដែលសរសេរជាភាសាខ្មែរ និងសំស្ក្រឹតមានចំនួនជាងមួយពាន់ផ្ទាំង ។ ក្នុងការស្ថាបនាឡើងវិញនូវប្រាសាទសំខាន់ៗជាច្រើននៅតំបន់អង្គរ ជន

ជាតិបារាំងបានស្វែងយល់ពីសាសនាកម្ពុជា ហើយតាមរយៈជំនឿទៅអំពីបាយ័នជនជាតិបារាំងក៏ស្វែងយល់ពីការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនផងដែរ ។

សិលាចារឹកទាំងនោះបង្ហាញអំពីការព្រួយបារម្ភរបស់ស្តេច (ជាទូទៅមានលក្ខណៈថ្លៃថ្នូរនិងសរសេរជាភាសាសំស្ក្រឹត) និងមួយចំនួនទៀតស្តីអំពីកិច្ចការរដ្ឋបាលអាណាចក្រ បើឲ្យច្បាស់ជាងនេះ កិច្ចការរដ្ឋបាលទាំងនេះគឺមានទំនាក់ទំនងទៅនឹងប្រាសាទដែលសាងសង់ឡើងដោយស្តេច ឬសមាជិកដ៏មានឥទ្ធិពលមួយរូបនៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់ ។

អ្នកសិក្សាទាំងនោះបានផ្តល់នូវការស្វែងយល់អំពីប្រាសាទ និងអ្វីៗទាំងអស់ពីការស្រាវជ្រាវរបស់ខ្លួនទៅពិភពលោកក្នុងនាមជាអំណោយមួយ ហើយពួកគេផ្តល់អំណោយមួយទៀតសម្រាប់ប្រជាជនកម្ពុជាផងដែរ ។

ប៉ុន្តែអ្វីដែលជាការខិតខំរបស់ជនជាតិបារាំងបានមើលរំលងនោះ គឺការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនសាមញ្ញនៅអង្គរ ដែលជាបុព្វបុរសរបស់អ្នកទាំងអស់គ្នាពុំមានការកត់ត្រាជាប្រវត្តិសាស្ត្រនូវជីវភាពនៃមនុស្សប្រុសស្រីរាប់រយរាប់ពាន់នាក់ដែលធ្វើស្រែចិញ្ចឹមបីបាច់គ្រួសារ ប្រយុទ្ធនៅក្នុងសង្គ្រាមដើម្បីអាណាចក្ររបស់ខ្លួន និងសាងសង់ប្រាសាទជាច្រើនផងទេ ។ បារាំងមើលឃើញអង្គរថាជាការតស៊ូមួយ ជាការប្រមូលនៃសម្រស់ដែលខូចខាតជាច្រើន និងជាទីតាំងសម្រាប់ប្រវត្តិសាស្ត្រាជានិយមដែលលាតសន្ធឹងក្នុងរយៈពេល៦០០ឆ្នាំ ។

ក្នុងរយៈពេលប្រមាណ៥០ឆ្នាំក្រោយនេះ មានការផ្លាស់ប្តូរមួយចំនួនទាក់ទងនឹងការគិតរបស់យើងចំពោះអង្គរ និងប្រវត្តិសាស្ត្រដើមនៃកម្ពុជា ។ ការគាស់កកាយលំនៅឋានចាស់ៗនៅសម័យមុនអង្គរ និងទីតាំងកប់សាកសពមួយចំនួនបានបង្ហាញអំពីភាពស្មុគស្មាញនៃការរស់នៅរបស់ប្រជាជនសាមញ្ញ ។ ការធ្វើផែនទីតំបន់អង្គរ ក៏ត្រូវបានគេប្រែក្លាយទៅជាសិល្បៈមួយដោយប្រើប្រាស់រូបភាពពីប្រព័ន្ធផ្កាយរណប ដើម្បីស្វែងរកវាលស្រែល្បីល្បើយ ប្រឡាយទឹក និងផ្លូវជាច្រើននៅអង្គរ ។ វាបានបង្ហាញថាអង្គរធ្លាប់ជាទីក្រុងដ៏ធំ និងកុះករមួយដែលផ្តល់ទីលំនៅដល់ប្រជាជនប្រមាណប្រាំពីរសែននាក់នៅសត-វត្សរ៍ទី១២ ជាពេលដែលអង្គរវត្តកំពុងត្រូវបានសាងសង់ឡើង ។

ឈ្មោះរបស់ទីក្រុងនេះគឺយសោធបុរៈ ។ ការពិតទៅ យើងដឹងច្រើនជាងអ្វីដែលយើងធ្លាប់បានដឹងស្តីពីទីក្រុងនេះចំពោះទម្រង់លំនៅឋាន ផ្លូវនានា របស់របរប្រើប្រាស់ ភាជន៍ និងប្រឡាយទឹកជាច្រើនទៀត ។ បុព្វបុរសប្រុសស្រីទាំងនោះបច្ចុប្បន្នបានលេចឡើងក្នុងនាមជាអ្នកស្រុកប្រកបដោយការច្នៃប្រឌិតនិងរស់រវើកក្នុងការកសាងទីក្រុងដ៏ធំស្មុគស្មាញ និងគួរឲ្យចាប់អារម្មណ៍មួយ បើទោះបីជាអ្នកទាំងនោះ ត្រូវបានចារនៅលើសិលាចារឹកក្នុងនាមជាទាសករក៏ដោយ ។ ក្រៅពីនោះ បុព្វបុរសទាំងនេះហើយដែលជាសិល្បករ និងស្ថាបត្យករដ៏អស្ចារ្យដែលយើងទាំងអស់គ្នាតែងតែស្គាល់ ។ អ្នកទាំងនេះហើយដែលជារូបអ្នកនោះ ។

ទន្ទឹមនឹងនេះដែរ ការសិក្សាតាមបែបបុរាណនៃបុរាណវិទ្យាចំពោះស្តេច ប្រាសាទ និងសិលាចារឹករបស់រាជាទាំងនេះបានផ្តល់នូវព័ត៌មានថ្មីៗជាច្រើននៅរជ្ជកាលស្តេចជ័យវរ្ម័នទី៧ ដូចជាអត្ថន័យនៃអង្គរវត្តតាមលក្ខណៈតារាសាស្ត្រនិងបុសគល់និងទំហំនៃការធ្វើពាណិជ្ជកម្មអន្តរជាតិ ។ នៅឆ្នាំ២០០៩ នេះយើងគ្រប់គ្នាបានដឹងអំពីប្រវត្តិសាស្ត្រច្រើនបំផុតលើអ្វី ដែលយើងធ្លាប់ដឹងក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សប្រុសស្រីនិងទីលំនៅរបស់បុព្វបុរសទាំងនេះ ដែលមានប្រមាណ១០០០គីឡូម៉ែត្រការ៉េ ។ ជួយពីការយល់ឃើញថាជាអាថ៌កំបាំងដ៏មហិមាមួយនោះ អង្គរគឺបានក្លាយទៅជាការរួមផ្សំនៃអាណាចក្រដ៏អស្ចារ្យមួយ និងស្នាដៃនៃបុព្វបុរសដែលភាសា ការរស់នៅ និងអត្តចរិត ដែលអ្នកទាំងអស់គ្នាយល់ថាគួរឲ្យចូលចិត្តនិងងាយស្រួលយល់ ។

## សម័យកណ្តាល-បរិវត្តន៍, ភាពឯកោ និងការគាបសង្កត់ពីខាងក្រៅ : ឆ្នាំ១៤៥០ ដល់ឆ្នាំ១៨៦៣នៃគ.ស ។

មិនមានឯកសារណាមួយនៅសេសសល់ដើម្បីប្រាប់យើងអំពីពេលវេលា និងមូលហេតុដែលនាំឲ្យអង្គរមានការធ្លាក់ចុះពីទីក្រុងដ៏អស្ចារ្យមួយនៅក្រោយសតវត្សរ៍ទី១៥នោះទេ ហើយដំណាក់កាលនេះពិតជាមានភាពស្មុគស្មាញណាស់ ដោយលាតសន្ធឹងរាប់រយឆ្នាំ ប៉ុន្តែបំលាស់ប្តូរនានាបានកើតឡើងរួចទៅហើយនៅក្នុងសង្គមខ្មែរជាច្រើនសតវត្សរ៍មុនរាជធានី យសោធបុរៈ (តែមិនមែនអង្គរវត្តទេ) ត្រូវបានបោះបង់ចោល ។

ចំណុចសំខាន់បំផុតនៃបម្រែបម្រួលនេះ គឺថាសង្គមកម្ពុជាដ៏ធំមួយបានផ្លាស់ប្តូរដោយការប្រែក្លាយទៅជាអ្នកកាន់និកាយពុទ្ធសាសនាថេរវាទវិញ ដែលប្រជាជនកម្ពុជាប្រណិប័តន៍ជាទូទៅនាពេលបច្ចុប្បន្ន ។ ការផ្លាស់ប្តូរនូវការប្រណិប័តន៍សាសនានេះ ប្រហែលជាកើតឡើងនៅសតវត្សរ៍ទី១៣ ព្រោះនៅពេលដែលអ្នកការទូតចិនម្នាក់មកធ្វើទស្សនកិច្ចរាជធានី យសោធរបុរៈ នៅក្នុងឆ្នាំ១២៩៦ ប្រជាពលរដ្ឋកំពុងតែប្រណិប័តន៍ព្រះពុទ្ធសាសនារួចទៅហើយ ។ បំលាស់ប្តូរនេះធ្វើឲ្យកម្ពុជាមានភាពស្រដៀងគ្នាទៅនឹងប្រទេសមួយដែលប្រតិបត្តិព្រះពុទ្ធសាសនាដូចគ្នានៅអំឡុងពេលជាមួយគ្នាដែរនោះ គឺប្រទេសសៀម ហើយពីរបីរយឆ្នាំក្រោយមក ឃើញមានការទទួលឥទ្ធិពលវប្បធម៌ពីគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរនេះ ។ ជាអកុសលសម្រាប់កម្ពុជា នៅក្នុងសតវត្សរ៍ទី១៦ ប្រទេសសៀមក្លាយទៅជាមានឥទ្ធិពលមួយ ហើយទទួលស្លួយសារអាករពីជនជាតិខ្មែរ ហើយបានបន្តធ្វើរហូតមកដល់ពេលបារាំងមកដល់នៅឆ្នាំ ១៨៦៣ ។ ប្រជាជនកម្ពុជាមិនបានចាញ់គ្រប់សង្គ្រាមទាំងអស់ដែលបានច្បាំងជាមួយនឹងសៀមទេ ហើយចំណុចមួយដែលកម្ពុជាបានចាញ់ គឺការបាត់បង់ចំនួនប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់នៅពេលដែលសៀមចាប់ជនជាតិខ្មែរជាឈ្លើយសឹក ។ ព្រឹត្តិការណ៍ដ៏សំខាន់នៅសម័យកណ្តាល គឺការរួញទឹកដីក្រោមការគ្រប់គ្រងដោយស្តេចខ្មែរមួយអន្តព្រមទាំងការបាត់បង់ប្រជាជនកម្ពុជាផង ។

បញ្ហាមួយទៀតសម្រាប់ប្រទេសកម្ពុជានៅក្នុងសម័យកណ្តាល គឺការលេចចេញជារូបរាងឡើងនូវប្រទេសជិតខាងដ៏មានឥទ្ធិពលមួយនៅប៉ែកខាងកើត ។ មកដល់សតវត្សរ៍ទី១៧ មេដឹកនាំត្រកូល ង្វៀន របស់វៀតណាមខាងត្បូងបានធ្វើឲ្យមានការបែកបាក់ក្នុងព្រះរាជវាំង រវាងអ្នកដែលធ្លាប់យកប្រទេសសៀមជាមេ និងអ្នកដែលត្រូវគ្នាជាមួយនឹងវៀតណាម ។ វៀតណាមក៏បានបិទច្រកផ្លូវទៅកាន់កំពង់ផែសមុទ្រ ហើយប្រហែលជាឆ្នាំ១៦៥០ ដល់១៨៥០ ព្រះរាជាណាចក្រនេះបានស្ថិតនៅក្នុងភាពឯកោពីពិភពខាងក្រៅ ហើយមានជំនួញដូរជាមួយអន្តរជាតិយ៉ាងតិចតួចបំផុត ។

ទោះជាយ៉ាងនេះក្តី មិនអាចនិយាយបានថាស្ថានភាពកម្ពុជាឋិតនៅក្នុងសភាពរងគ្រោះនិងហិនហោចនោះទេ ។ សម័យនេះហើយដែលសមិទ្ធផលអក្សរសាស្ត្រខ្មែរមួយចំនួនបានផុសត្រដែតឡើង ដូចជាច្បាប់នានានិងរឿងរាមកេរ្តិ៍ជាដើមហើយ សម័យនេះហើយដែលបានផ្សារភ្ជាប់អរិយធម៌អង្គរ ទៅនឹងសង្គមមួយដែលបារាំងបានជួបប្រទះពេលមកដល់ប្រទេសនេះដំបូងនៅឆ្នាំ១៨៦០ ។ ការផ្សារភ្ជាប់រវាងអង្គរនិងសម័យអាណានិគម រួមមានវប្បធម៌ដ៏ត្រចះត្រចង់របស់ខ្មែរភាសាដែលពោរពេញទៅដោយភាព

សម្បូរបែប និងភាពត្រចះត្រចង់នៃការរៀបចំសង្គម ។ ម៉្យាងវិញទៀត ជនជាតិខ្មែរ គឺជាអ្នកទទួលមរតកនៃសម័យកាលនេះប្រហែលជាច្រើនជាងសម័យអង្គរ ឬសម័យអាណានិគមទៅទៀត ។

## សម័យអាណានិគម-សង្គមកម្ពុជាចាប់ផ្តើមបើកចំហទៅពិភពខាងក្រៅច្រើនជាងមុន ៈ ឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ ។

នៅពេលដែលអ្នករុករកជាតិបារាំងមកដល់ទឹកដីកម្ពុជានៅទសវត្សរ៍៦០ ជនជាតិបារាំងទាំងនោះកំពុងតែរុករកទីតាំងដើម្បីពង្រីកផលប្រយោជន៍ពាណិជ្ជកម្មរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ ហើយពួកគេមានជំនឿថា កម្ពុជា ឬប្រហែលជាទន្លេមេគង្គគឺជាទ្វារទឹកដ៏សំខាន់ទៅកាន់ប្រទេសចិន ។ នៅពេលនោះ បារាំងបានកាន់កាប់វៀតណាមខាងត្បូងជាអាណានិគមរួចទៅហើយ ហើយមានបំណងចង់ពង្រីកការគ្រប់គ្រងលើទឹកដីអាស៊ីអាគ្នេយ៍ទាំងមូល ។

សង្គ្រាមស៊ីវិល អំពើបះបោរ ការឈ្លានពានពីសំណាក់សៀម និងការបិតនៅក្រោមអាណាព្យាបាលរបស់វៀតណាមអស់រយៈពេលដ៏យូរអង្វែងបានរឹតរួតប្រទេសកម្ពុជាអស់រយៈពេល ៥០ឆ្នាំ ។ កងទ័ពថៃនិងវៀតណាមបានប្រយុទ្ធគ្នានៅលើទឹកដីកម្ពុជា ហើយសង្គ្រាមនេះបានបង្កវិនាសកម្មដល់ប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាបានបាត់បង់ជីវិតយ៉ាងច្រើនសន្ធឹកសន្ធាប់ វត្តអារាមជាច្រើនត្រូវបានបំផ្លាញ ហើយព្រះរាជាដែលទើបតែឡើងសោយរាជបល្ល័ង្កថ្មីគឺព្រះបាទ នរោត្តម ដែលធ្លាប់តែខ្វបខ្វាចសៀមបានស្វែងរកការការពារពីប្រទេសបារាំង (ឬបើជាក់ច្បាស់ជាងនេះទៅទៀតព្រះអង្គបានទទួលយកនូវអ្វីដែលបារាំងបានដាក់អាណាព្យាបាល) ។ បារាំងមានការពេញចិត្តនឹងការធ្វើជាអាណាព្យាបាលរបស់ប្រទេសកម្ពុជា ប៉ុន្តែព្រះបាទ នរោត្តម មានការភ្ញាក់ផ្អើលហើយមិនពេញចិត្តត្រង់ថា បារាំង បានគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងនយោបាយប្រមាណជា៣០ឆ្នាំក្រោយមក ។ ព្រះមហាក្សត្រក្លាយជាបុគ្គលដែលគ្មានសារសំខាន់ ។ ទោះបីប្រទេសកម្ពុជាមានឈ្មោះជាផ្លូវការថាស្ថិតក្រោមអាណាព្យាបាលបារាំង ហើយមានព្រះមហាក្សត្រដឹកនាំក៏ដោយ ក៏មកដល់ចុងសតវត្សរ៍ទី១៩ ប្រទេសបារាំងបានដាក់ប្រទេសកម្ពុជាជាអាណានិគមរួចទៅហើយដែរ ហើយបារាំងដែលបានសាងវិមានសម្រាប់ខ្លួនឯង និងបានតាំងខ្លួនជាអ្នកដែលដើរតួយ៉ាងសំខាន់ក្នុងការសម្រេចកិច្ចការសំខាន់ៗនៅប្រទេសកម្ពុជា ហើយបារាំងជាអ្នកលើកបន្តុបព្រះមហាក្សត្រខ្មែរបីអង្គទៀតនាដំណាក់កាលក្រោយមកទៀត ។

ដើម្បីថ្លឹងថ្លែងមើលអំពីគុណភាពនៃអាណានិគមនិយមបារាំងនៅប្រទេសកម្ពុជា ជាការសំខាន់ណាស់ដែលត្រូវកំណត់ចំណាំថា បារាំងបានរួមចំណែកក្នុងការកសាងជាច្រើនផងដែរ (ដោយការប្រើប្រាស់ពលករខ្មែរដើម្បីស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំទីក្រុង និងការស្រាវជ្រាវផ្នែកបុរាណវិទ្យា) ។ ទីប្រជុំជនត្រូវបានរៀបចំជាគម្រោង ហើយត្រូវបានរៀបចំឡើងដោយពួកអ្នកមាន ។ ចំណែកឯផ្លូវថ្នល់វិញក៏ត្រូវបានកសាងឡើងដែររួមទាំងផ្នែកផ្សេងៗនៃទីក្រុងភ្នំពេញផង ។ វាគឺងាយនឹងមើលឃើញណាស់ថាការកសាងទាំងនេះគឺដើម្បីជាប្រយោជន៍ដល់បារាំងច្រើនជាងដើម្បីខ្មែរ ។ បារាំងធ្វើការសិក្សាលើផ្នែកបុរាណវិទ្យារបស់ខ្មែរ ផ្ទុយទៅវិញ ខណៈពេលដែលការធ្វើបែបនេះបារាំងបាននាំយកនូវកិត្តិយសដល់ប្រទេសរបស់ខ្លួនក៏ពិតមែន តែការសិក្សាពីបុរាណវិទ្យានេះបានផ្តល់ជាប្រយោជន៍ដល់ខ្មែរហើយប្រហែលជាកេរដំណែលមួយដ៏ល្អប្រពៃតែគួរឲ្យឈឺចាប់ផងដែរ ។

នៅពេលខេត្តបាត់ដំបង និងសៀមរាប ដែលធ្លាប់ជាខេត្តចំណុះរបស់សៀមក្នុងឆ្នាំ១៧៩០ត្រូវបានប្រគល់ឲ្យកម្ពុជាវិញក្រោយពីបារាំងដាក់សម្ពាធទៅលើថៃ តំបន់អង្គរក៏ត្រូវបានកាន់កាប់ដោយខ្មែរឡើងវិញ ដូច្នេះបុរាណវិទូបារាំងអាចចាប់ផ្តើមធ្វើការ ដោយប្រើប្រាស់កម្មករខ្មែរក្នុងកិច្ចការជួលជុលប្រាសាទបុរាណឡើងវិញ ។ មានចំណុចអវិជ្ជមានខ្លះនៃរបបអាណានិគមដែលខ្ញុំនឹងលើកមកពិភាក្សានៅពេលបន្តិចទៀតនេះ ។ ខ្ញុំគិតថា បើយើងមើលពីឆ្នាំ២០០៩នេះថយទៅក្រោយ យើងអាចនិយាយបានថា បារាំងមិនបានបំផ្លិចបំផ្លាញកម្ពុជាច្រើនដូចអ្វីដែលបានខូចខាតដោយឥទ្ធិពលបរទេសក្នុងអំឡុងសង្គ្រាមវៀតណាម និងអំឡុងសង្គ្រាមរវាងខ្មែរនិងខ្មែរ ខ្មែរនិងបរទេស ក្រោយមកទៀត ឬក្រោមរបបខ្មែរក្រហមនោះទេ ។ ជាមួយគ្នានោះដែរ សម័យអាណានិគមបានបន្សល់នូវទិដ្ឋភាពអវិជ្ជមានជាច្រើនផងដែរ ហើយទិដ្ឋភាពខ្លះបានបន្តមកដល់ឆ្នាំ២០០៩នេះទៀត ។

ប្រហែលជាចំណុចអវិជ្ជមានដ៏សំខាន់មួយគឺថា អាណាព្យាបាលបារាំងមិនបានអប់រំបណ្តុះបណ្តាលប្រជាជនកម្ពុជា ហើយមិនបានផ្តល់ឱកាសដល់ប្រជាជនកម្ពុជាក្នុងការចូលរួមក្នុងឆាកនយោបាយទេនាដំណាក់កាលមុនឆ្នាំ១៩៤០ ។ បារាំងបានរៀបចំប្រទេសក្នុងសភាពមិនបានល្អទេ ។ រហូតមកដល់សម័យសង្គ្រាមលោកលើកទី២ ប្រទេសទាំងមូលមានវិទ្យាល័យតែមួយគត់ហើយគ្មានមហាវិទ្យាល័យនោះទេ ។

ចំណុចដែលមើលទៅមានភាពខ្វះខាតនៅក្នុងសម័យអាណានិគមដែរនោះ គឺប្រព័ន្ធតុលាការ ។ បារាំងមិនបានកំណត់ប្រព័ន្ធយុត្តិធម៌ច្បាស់លាស់ឡើយ ហើយសឹងតែគ្មានមេធាវីនិងចៅក្រមជាជនជាតិខ្មែរណាដែលទទួលបាននូវការបណ្តុះបណ្តាលផ្នែកច្បាប់គ្រប់គ្រាន់ដែរ ។

ទោះជាយ៉ាងណា បារាំងបានរួមចំណែកផ្តល់នូវផលវិជ្ជមានដល់កម្ពុជាផងដែរ ដូចជាកម្ពុជាបានរួចរស់ជីវិតហើយបានក្លាយជារដ្ឋមួយឯករាជ្យ ដោយគ្មានការជ្រៀតជ្រែកពីសំណាក់ប្រទេសជិតខាងដែលមើលទៅដូចជាមានសភាពទន់ជ្រាយណាស់ទៅហើយមុននឹងបារាំងមកដល់ ។ បារាំងក៏មិនបានជួយខ្មែរឲ្យច្រើនដូចអ្វីដែលខ្លួនបានបង្កើនអំណាច និងឥទ្ធិពលរបស់ខ្លួនទេ ។

ក្នុងឆ្នាំ១៩៧៥ អ្នកនាំពាក្យខ្មែរក្រហមម្នាក់បានប្រកាសដោយមោទនភាពថា «២០០០ឆ្នាំ» នៃប្រវត្តិសាស្ត្រកម្ពុជាបានមកដល់ទីបញ្ចប់ ។ ខ្ញុំសង្ឃឹមថា ខ្ញុំបានបកស្រាយយ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍សង្ខេបមួយនេះ ដោយមិនត្រឹមតែបានរៀបរាប់ប្រវត្តិកម្ពុជាត្រឡប់ទៅលើសពី ២០០០ឆ្នាំប៉ុណ្ណោះនោះទេ រឿងនេះថែមទាំងជារឿងដែលគួរឲ្យចាប់អារម្មណ៍ ហើយក៏ជារឿងដែលជនជាតិកម្ពុជាមានមោទនភាពណាស់ ។

ដេវីដ ឆេនល័រ គឺជាសាស្ត្រាចារ្យចូលនិវត្តន៍ម្នាក់ដែលបង្រៀនផ្នែកប្រវត្តិវិទ្យានៅសកលវិទ្យាល័យ ម៉ូណាស់ ។ លោកបណ្ឌិត ឆេនល័រ គឺជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រដ៏ល្បីល្បាញម្នាក់ទាក់ទងនឹងរឿងរ៉ាវរបស់ប្រទេសកម្ពុជា ដែលបានបោះពុម្ពស្នាដៃនិពន្ធរបស់គាត់នៅក្នុងសៀវភៅរួមមានដូចជា "សោកនាដកម្មរបស់ប្រវត្តិសាស្ត្រកម្ពុជា : នយោបាយ សង្គ្រាម និងការបដិវត្តន៍តាំងពីឆ្នាំ១៩៤៥" "បងធំទីមួយ : ប្រវត្តិនយោបាយរបស់ប៉ុលពត" និង "សំឡេងចេញពីមន្ទីរស-២១" ។ គាត់គឺជាអ្នកប្រឹក្សាចម្បងមួយរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងការអភិវឌ្ឍន៍សៀវភៅ ។